# ឧបសម្បទាវិធី


រៀបរៀងដោយ

**ម៉ាន់ ចាន់សារ៉ែន**



ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា

នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា

**ព.ស.២៥៥៧**

---

**គ.ស.២០១៣**

ឈ្មោះសៀវភៅ ឧបសម្បទាវិធី

អ្នករៀបរៀង ខ៊ាន់ ចាន់សារ៉ែន

កាលបរិច្ឆេទរៀបរៀង ព.ស.២៥៤៧ , គ.ស.២០០៤

កាលនៅជាក្រុមជំនុំព្រះត្រៃបិដកវិទ្យាស្ថាន

ពុទ្ធសាសនបណ្ឌិត្យ

Printed for free distribution by

**The Corporate Body of the Buddha Educational Foundation**

11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.

Tel: 886-2-23951198 , Fax: 886-2-23913415

Email: overseas@budaedu.org

Website:http://www.budaedu.org

Mobile Web: m.budaedu.org

**This book is strictly for free distribution, it is not to be sold.**

សម្រាប់ចែកជាធម្មទាន

# មាតិកា


| ល.រ. | មាតិកាអត្ថបទ | ទំព័រ |
|---|---|---|
| ១. | អារម្ភកថា | ក |
| ២. | ឧបសម្បទាវិធី | ១ |
| ៣. | ការផ្លាស់បកតិនាម | ៣ |
| ៤. | ការសន្មតិឧបជ្ឈាយ៍និងនាគ | ៤ |
| ៥. | សួរអន្តរាយិកធម៌ | ៦ |
| ៦. | ហៅនាគចូលជំនុំសង្ឃ | ៩ |
| ៧. | សួរអន្តរាយិកធម៌ក្នុងកណ្តាលជំនុំសង្ឃ | ១០ |
| ៨. | សូត្រញត្តិចតុត្ថកម្មវាចាសម្រាប់នាគមួយ | ១៣ |
| ៩. | វិធីផ្លាស់ឈ្មោះបាលីតាមឈ្មោះនាគ | ១៧ |
| ១០. | ឧបសម្បទាវិធីអាចារ្យមួយរូប សិស្ស(នាគ) ២ ឬ ៣រូប | ១៩ |
| ១១. | ប្រៀនប្រដៅនាគ | ២១ |
| ១២. | ហៅនាគចូលមកកាន់ការកសង្ឃ | ២៣ |
| ១៣. | សួរអន្តរាយិកធម៌ក្នុងកណ្តាលជំនុំសង្ឃ | ២៤ |
| ១៤. | ញត្តិចតុត្ថកម្មវាចាសម្រាប់នាគគូ | ២៥ |

១៥.ឧបសម្បទាបេក្ខទទួលសមាសូបសម្បទាកម្មវាចា...................... ៣០
១៦.តាំងញត្តិទី១...................................................................... ៣០
១៧.អនុស្សានាទី១ ទី២............................................................. ៣១
១៨.ឧបសម្បទាវិធីកំណោត់ឧបសម្បទាបេក្ខថា នាគទាំងអស់.......... ៣៤
១៩.តាំងញត្តិទី១...................................................................... ៣៤
២០.អនុស្សាវនាទី១ ទី២............................................................ ៣៥
២១.អនុសាសនវិធី .................................................................... ៣៦
២២.និស្ស័យទី១........................................................................ ៣៧
២៣.និស្ស័យទី២........................................................................ ៣៨
២៤.និស្ស័យទី៣........................................................................ ៣៩
២៥.និស្ស័យទី៤........................................................................ ៤០
២៦.អករណីយកិច្ចទី១................................................................ ៤១
២៧.អករណីយកិច្ចទី២................................................................ ៤២
២៨.អករណីយកិច្ចទី៣................................................................ ៤៣
២៩.អករណីយកិច្ចទី៤................................................................ ៤៥
៣០.និគមនកថា.......................................................................... ៤៧
៣១.ឯកសារពិគ្រោះ................................................................... ៤៩

# អារម្ភកថា

ព្រះពុទ្ធសាសនាមានលំអ ៣ យ៉ាងគឺ អាទិកល្យាណ មជ្ឈេកល្យាណ បរិយោសានកល្យាណ ក្នុងលំអ ៣ យ៉ាងនេះយើងត្រូវជ្រាបថា អាទិក-ល្យាណបានដល់ព្រះវិន័យ ដែលជាពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាតរបស់ព្រះសម្មាសម្ពុទ្ធ ។ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានវិន័យគ្រប់គ្រង មានវិន័យជាសាស្តា បើប្រាសចាកវិន័យហើយមិនអាចឈ្មោះថា ជាភិក្ខុបានឡើយ ដូចឧបសម្បទាវិធីព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតថា **អនុជានាមិ ភិក្ខវេ ញត្តិចតុត្ថេន កម្មេន ឧបសម្បទំ** ម្នាលភិក្ខុទាំងឡាយ ឥឡូវតថាគតអនុញ្ញាតញត្តិចតុត្ថកម្ម គឺកម្មមានញត្តិជាគម្រប់ ៤ វិញ ។ នេះជាពុទ្ធានុញ្ញាតដែលព្រះអង្គទ្រង់ឱ្យបព្វជិតក្នុងសាសនាព្រះអង្គនេះ បួសជាភិក្ខុដោយវិធីបែបនេះឯង ។ បើសិនជាយើងទៅធ្វើវិធីបែបផ្សេងៗដែលប្រាសចាកវិន័យនេះ ពិតជាមិនត្រឹមត្រូវតាមព្រះពុទ្ធសាសនាឡើយ ។ ដោយសេចក្តីជ្រះថ្លាក្នុងព្រះវិន័យទើបខ្ញុំបានប្រមូលគម្ពីរ វិនយបិដក មហាវគ្គ ភាគ៦ សមន្តប្បាសាទិកា វជិរពុទ្ធិដីកា សារត្ថទីបនីដីកា វិមតិវិនោទនីដីកា វិនយាលង្ការដីកា បានប្រែទឹងត្រួតពិនិត្យអត្ថនិងព្យញ្ជនៈសព្វគ្រប់ហើយ

ទើបរៀបរៀងកូនសៀវភៅនេះឡើង ។ តាមបោរាណាចារ្យធ្លាប់កំណត់តំខណិកនាម ឧបជ្ឈាយ៍ថា **តិស្សៈ** ឧបសម្បទាបេក្ខៈថា **នាគៈ** ក៏ខ្ញុំបានធ្វើតាមបែបបោរាណាចារ្យដែលធ្លាប់បានធ្វើមកហើយថែមទាំងអាងដល់គម្ពីរដែលព្រះគន្ថរចនាចារ្យពោលទុកដូច សារត្ថទីបនីដីកា ( ៣/ ៣២៣)និង វិនយាលង្ការដីកា ( ១/២៤៤ ) ថា **យេន កេនចិ នាមេន អនុស្សាវនា កាតព្វាតិ វទន្តិ** អាចារ្យទាំងឡាយពោលថា គួរធ្វើការសូត្រកម្មវាចាដោយឈ្មោះយ៉ាងណាមួយក៏បានដែរ ។ វិមតិវិនោទនីដីកា (២/១២៨) ពោលថា **គោត្តាទិនាមេន តំខណិកនាមេន ច អនុស្សាវនំ កាតុំ វដ្ដតិ តស្មីបិ ខណេ អយំ តិស្សោតិ វា នាគោតិ វា នាមំ ករោន្តេហិ អនុសាសកសម្មុតិតោ បឋមមេវ កាតព្វំ ។** ឧបសម្បទាចារ្យគួរសូត្រកម្មវាចាដោយឈ្មោះគោត្រជាដើមឬតំខណិកនាម សូម្បីក្នុងខណៈនោះឧបសម្បទាចារ្យគួរតាំងឈ្មោះ ឧបជ្ឈាយ៍ថា **តិស្សៈ** ឧបសម្បទាបេក្ខៈថា **នាគៈ** មុននឹងសម្មតិខ្លួនឯង ។ ដូច្នេះក្នុងសៀវភៅនេះ ខ្ញុំក៏បានរៀបរៀងតាមគម្ពីរទាំងអស់មិនបានបញ្ចេញបញ្ចូលមតិខ្លួនឯងនោះទេ ។

ខ្ញុំធ្លាប់បានឃើញការលំបាកស្មុគស្មាញជាច្រើនដល់ឧបសម្បទាចារ្យ ដែលត្រូវការបំបួសកុលបុត្រច្រើន ឃើញសូត្រម្ដងមួយអង្គៗ ទម្រាំបានរួចស្រេចពីឧបសម្បទានោះ ព្រោះហេតុនោះ ទើបខ្ញុំចាប់រៀបចំនូវឧបសម្បទាបែបនេះឡើង ទោះបីថានៅក្នុងប្រទេសកម្ពុជាយើងអ្នកប្រាជ្ញបានរៀបចំសៀវភៅឧបសម្បទាជាច្រើនក៏ដោយ តែសៀវភៅទាំងនោះ មិនឃើញមានការរៀបចំបួសម្ដងបាននាគ ២ ឬ ៣ឡើយ ។ ដោយឃើញមិនមានឯកសារណានីមួយរៀបចំបួសម្ដងបាន ២ ឬ ៣ នោះ ទើបខ្ញុំរៀបចំឯកសារនេះឡើងដែលមានការបួសម្ដង ២ ឬ ៣ ជាការងាយស្រួលដល់ឧបជ្ឈាយ៍ និងឧបសម្បទាចារ្យ ដែលត្រូវការបំបួសនាគម្ដងច្រើនកុំឱ្យស្មុគស្មាញខូចវេលាយូរនិងជាការងាយស្រួលក្នុងការបំបួសកុលបុត្រទៀតផង ។

ខ្ញុំសង្ឃឹមថា កូនសៀវភៅនេះនឹងសម្រេចប្រយោជន៍ដល់កុលបុត្រអ្នកប្រាថ្នាប្រយោជន៍ក្នុងព្រះពុទ្ធសាសនាមិនខានទេ ។

ដោយបានជួយឧបត្ថម្ភពីក្រុមនាទីទ្រទ្រង់ព្រះត្រៃបិដកនៃវិទ្យា-ស្ថានពុទ្ធសាសនបណ្ឌិត្យឱ្យខ្ញុំព្រះករុណាខ្ញុំបាទជួយធ្វើគម្ពីរដើម្បីផ្សព្វផ្សាយព្រះពុទ្ធសាសនា ដោយបានជួយកុំព្យូទ័រមួយគ្រឿងនិងសម្ភារៈផ្សេងៗ

ទៀត ។ ឯកសារនេះខ្ញុំព្រះករុណា ខ្ញុំបាទបានធ្វើរួចស្រេច តាំងពីថ្ងៃ ច័ន្ទ ៤ រោច ខែ មិគសិរ ឆ្នាំ មមី ចត្វាស័ក ព.ស.២៥៤៦ គ.ស. ២០០២ ម្ល៉េះ តែមិនទាន់មានថវិកាបោះពុម្ពនៅឡើយ តែឥឡូវខ្ញុំព្រះករុណា ខ្ញុំបាទបាន មកធ្វើការជាក្រុមជំនុំព្រះត្រៃបិដកប្រចាំវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ក៏ បានឱកាសក្នុងការបោះពុម្ពផ្សព្វផ្សាយឡើង ។ បច្ចុប្បន្ននេះក្រុមជំនុំព្រះ ត្រៃបិដកយើងខ្ញុំ ប្រចាំវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យកំពុងធ្វើសៀវភៅជា ច្រើន ដើម្បីប្រយោជន៍ដល់ព្រះពុទ្ធសាសនា ដើម្បីជាប្រយោជន៍ដល់ព្រះ សង្ឃនិងសៀវភៅជំនួយដល់សមណសិស្ស កុលបុត្រនិងពុទ្ធសាសនិកជន គ្រប់ជាន់ថ្នាក់ទាំងអស់ ដែលមានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ។

ពុទ្ធសាសនបណ្ឌិត្យ

ថ្ងៃ ពុធ ៣ កើត ខែ មិគសិរ ឆ្នាំ មមែ បញ្ចស័ក ព.ស. ២៥៤៧

ត្រូវនឹងថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០០៣

**វ៉ាន់ ចាន់សារ៉េន**

ក្រុមជំនុំព្រះត្រៃបិដកប្រចាំវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ



ព្រះភិក្ខុ វ៉ាន់ ចាន់សារ៉ឿន



អ៊ាន់  ចាន់សារ៉េន

កាលនៅធ្វើការជាក្រុមជំនុំព្រះត្រៃបិដកវិទ្យាស្ថាន

ពុទ្ធសាសនបណ្ឌិត្យ

# ឧបសម្បទាវិធី

វិធីដែលនឹងឧបសម្បទាកុលបុត្រឱ្យឡើងជាភិក្ខុនោះ កុលបុត្រដែលត្រូវបួសជាភិក្ខុត្រូវស្វែងរកបាត្រ សង្ឃាដី ចីវរ ស្បង់ឱ្យគ្រប់គ្រាន់ជាមុន ហើយត្រូវធ្វើច្បាប់ចូលកាន់ផ្នួសឱ្យបានត្រឹមត្រូវតាមច្បាប់ប្រទេសជាតិ ។

កាលដល់ថ្ងៃឧបសម្បទឧបជ្ឈាយ៍ឬអាចារ្យគឺគ្រូសូត្រ ត្រូវនិមន្តព្រះភិក្ខុជាបកតត្តៈដែលបួសត្រឹមត្រូវយ៉ាងតិចប្រាំអង្គព្រមទាំងឧបជ្ឈាយ៍ ឱ្យចូលទៅកាន់សីមា បើមានព្រះភិក្ខុនៅក្នុងសីមាតែមួយជាមួយគ្នា ត្រូវនិមន្តមកទាំងអស់ សូម្បីតែមួយអង្គក៏មិនត្រូវឱ្យនៅក្នុងសីមានោះដែរ លើកលែងតែភិក្ខុដែលបានឱ្យឆន្ទៈ និង បារិសុទ្ធិមក ។

កាលបើនិមន្តភិក្ខុមកជួបជុំគ្នាហើយ ត្រូវលៃលកចាត់ចែងឱ្យភិក្ខុទាំងនោះគង់ឱ្យត្រូវហត្ថបាសគឺ ១ ហត្ថ ១ ចំអាមអំពីគ្នានឹងគ្នា សូម្បីឧបជ្ឈាយ៍ក៏ត្រូវគង់ឱ្យជាប់ហត្ថបាសដែរ មិនមែនថាឧបជ្ឈាយ៍ត្រូវគង់ឱ្យឆ្ងាយពីគេព្រោះលោកចាស់ មិនមែនដូច្នោះទេ ហ៊ានតែភិក្ខុណាមួយឃ្លាតពីហត្ថបាស

១ហត្ថ១ចំអាម ការឧបសម្បទាជាភិក្ខុនោះមិនអាចឡើងឡើយ។ ដូច្នោះក្នុងពិធីឧបសម្បទានេះ សូមឧបជ្ឈាយ៍ ឬ អាចារ្យពិនិត្យហើយពិនិត្យទៀតរឿងហត្ថបាសនេះ (នៅក្នុងគម្ពីរកង្ខាវិតរណី-អភិនវដីកា ឈ្មោះ វិនយត្ថ-មញ្ជូសា ទំព័រ ១៤៥ និងអត្ថយោជនា សមន្តប្បាសាទិកា ភាគ ២ ទំព័រ ២៤៩ ព្រះគន្ថរចនាចារ្យខែពន្យល់ថា **ហត្ថបាសោ នាម ទិយឌ្ឍហត្ថ-ប្បមាណោ** ទីប្រមាណ ១ ហត្ថ ១ ចំអាម ឈ្មោះថា **ហត្ថបាស** (នៃសង្ឃកម្ម) អត្ថយោជនាដដែលទំព័រ ២៧៤ ខែថា **ហត្ថបាសោតិ ទិយឌ្ឍ-ហត្ថប្បមាណោ** , ក៏ការរាប់ហត្ថបាសសង្ឃកម្មនេះនៅក្នុងគម្ពីរអនុវណ្ណ-នាដីកាបាតិមោក្ខ ទំព័រ ២២ ព្រះគន្ថរចនាចារ្យខែពន្យល់ថា **ឯតេន ទិយឌ្ឍហត្ថប្បមាណោ បទេសោ គហេតព្វោ ន ទ្វាទសហត្ថ-បាសោ ។ ឥធ ដីកាយំ អាគតោ ទិយឌ្ឍហត្ថបាសោ អញ្ញ-មញ្ញវសេន បរិវត្តហណសិក្ខាបទេ អាគតោ អឌ្ឍតេយ្យហត្ថបាសោ ភិក្ខុបធានវសេន វេទិតព្វោ ។** បណ្ឌិតគប្បីកាន់យកនូវទីប្រមាណ ១ ហត្ថ ១ ចំអាមថា ជាហត្ថបាសសង្ឃកម្ម មិនមែន ១២ ហត្ថនោះទេ , ហត្ថបាស ១ ហត្ថ ១ ចំអាម ដែលមានមកក្នុងដីកានេះ បណ្ឌិតគប្បីកាន់

យកដោយអំណាចនៃភិក្ខុទៅវិញទៅមក (ចំណែក)ទីហត្ថបាសដែលមានប្រមាណ ២ ហត្ថ ១ ចំអាមមានមកក្នុងបដិគ្គហណសិក្ខាបទ (ទន្តបោណ-សិក្ខាបទ) បណ្ឌិតគប្បីកាន់យកដោយអំណាចនៃភិក្ខុជាប្រធាន ។ ដូច្នេះការវាស់ហត្ថបាសក្នុងទន្តបោណសិក្ខាបទ ផ្សេងពីហត្ថបាសនៃសង្ឃកម្មទាំងស្រុងមិនដូចគ្នាទេ វិធីវាស់ក្នុងទន្តបោណសិក្ខាបទគឺបើភិក្ខុគង់ ហើយមានទាយកប្រគេនចង្ហាន់ត្រូវវាស់ពីបិដ្ឋិ (ខ្នង)លោកមក...នៅសល់តែ ១ ហត្ថ ១ ចំអាមពីទ្រូងមក តែចំណែកហត្ថបាសសង្ឃកម្មមិនវាស់ដូចគ្នាទេ គឺវាស់ ១ ហត្ថ ១ ចំអាមពីភិក្ខុមួយទៅភិក្ខុមួយតែម្តង ឥតមានវាស់ពីម្ខាងអស់ ១ ហត្ថនៅសល់តែ ១ ចំអាមនោះទេ, សូមអ្នកសិក្សាពិចារណាមើលក្នុងវចនានុក្រមខ្មែរ ភាគទី ១-២ បោះពុម្ព ព.ស. ២៥១១ គ.ស. ១៩៦៧ នៅត្រង់ទំព័រ ១៥០៧ បន្ទាត់ទី ១៤ ហើយពិនិត្យជាមួយគម្ពីរដែលពោលមកខាងដើមរួចពិចារណាមើលចុះ ) ។

ចំណែកកុលបុត្រដែលត្រូវបួសជាភិក្ខុនោះ ត្រូវស្ពាយបាត្រក្រោកឈរឡើង ដើរឱ្យទៅដល់កណ្តាលការកសង្ឃស្ថិតត្រង់ទីចំពោះមុខព្រះឧប-ជ្ឈាយ៍ ទើបឧបសម្បទាចារ្យគឺគ្រូសូត្រផ្លាស់ **បកតិនាម** ដែលមិនសមគួរ

តាមភាសាបាលី ហើយសន្មតឱ្យឈ្មោះជា **តំខណិកនាម** វិញថា ៖

**ត្វំ នាគោ នាម** "អ្នកឈ្មោះនាគ"។ ឧបសម្បទាបេក្ខៈត្រូវទទួលថា ៖

**ឧកាស អាម ភន្តេ ។** ហើយឧបសម្បទាចារ្យសន្មតនាមព្រះឧបជ្ឈាយ៍

តំខណិកនាមថា ៖ **តុយ្ហំ ឧបជ្ឈាយោ អាយស្មា តិស្សត្ថេរោ នាម**។

ត្រូវទទួលថា ៖ **ឧកាស អាម ភន្តេ ។**

បន្ទាប់មកឧបសម្បទាចារ្យសូត្រនមស្ការ ៣ ដងថា ៖

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។** ហើយគប្បី

យកម្រាមដៃចង្អុលប្រាប់បាត្រត្រៃចីវរថា ៖

- **អយន្តេ បត្តោ ។**

ត្រូវទទួលថា ៖ **អាម ភន្តេ ។**

- **អយំ សង្ឃាដិ ។**

ត្រូវទទួលថា ៖ **អាម ភន្តេ ។**

- **អយំ ឧត្តរាសង្គោ ។**

ត្រូវទទួលថា ៖ **អាម ភន្តេ ។**

**- អយំ អន្តរវាសកោ ។**

ត្រូវទទួលថា ៖ **អាម ភន្តេ ។**

**- គច្ឆ អមុម្ហិ ឱកាសេ តិដ្ឋាហិ** "អ្នកចូលចេញទៅឈរក្នុងទីឱកាសឯណោះ" ។

ឧបសម្បទាបេក្ខៈ ត្រូវថយចេញទៅឱ្យផុត អំពីហត្ថបាសការកសង្ឃ ហើយប្រណម្យអញ្ជលី,ទើបឧបសម្បទាចារ្យសូត្រប្រកាសសង្ឃថា៖

**សុណាតុ មេ ភន្តេ សង្ឃោ, នាគោ អាយស្មតោ តិស្សស្ស ឧបសម្បទាបេក្ខោ, យទិ សង្ឃស្ស បត្តកល្លំ អហំ នាគំ អនុសាសេយ្យំ ។**

លុះសូត្រប្រកាសសង្ឃស្រេចហើយ ទើបលោកចេញទៅឈរចំពោះមុខជិតគ្នានឹងនាគហើយលោកសូត្រប្រៀនប្រដៅថា ៖

**សុណសិ នាគ អយន្តេ សច្ចកាលោ ភូតកាលោ យំ ជាតំ តំ សង្ឃមជ្ឈេ បុច្ឆន្តេ សន្តំ អត្ថីតិ វត្តព្វំ អសន្តំ នត្ថីតិ វត្តព្វំ មា**

**ខោ វិត្ថាយិ (១) មា ខោ មង្កុ អហោសិ ឯវន្តំ បុច្ឆិស្សន្តិ សន្តិ តេ ឯវរូបា អាពាធា ។**

ហើយត្រូវសួរអាពាធទាំង ៥ យ៉ាងដូច្នេះថា ៖

**- កុដ្ឋំ** "ឃ្លង់" ។

ត្រូវទទួលថា ៖ **នត្ថិ ភន្តេ** ។

**- គណ្ឌោ** "ពក ឬ បូស" ។

ត្រូវទទួលថា ៖ **នត្ថិ ភន្តេ** ។

**- កិលាសោ** "រោគស្រែង" ។

ត្រូវទទួលថា ៖ **នត្ថិ ភន្តេ** ។

---

(១)**វិត្ថាយិ** នេះជាបទឆដ្ឋសង្ខាយនាមកពី **វិ** បុព្វបទ **ថេ** ធាតុ នឹង អជ្ជត្តនី ក្នុងវេលាប្រកបបបំមាវិភត្តិនឹងមានរូបជា **វិត្ថាយតិ . វិត្ថាយន្តិ** ដូចក្នុងវិនយបិដកលេខ ៦ ឃើញមានរូបជា វិត្ថាយន្តិ ត្រង់ទំព័រ ៣០៧ ជាដើម ។ ពាក្យថា **វិត្ថាយិ** នេះមានប្រាកដក្នុង បបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយនិងសមន្តប្បាសាទិកា អដ្ឋកថា វិន័យ ។ ធាតុដែលជា ឯកសរឯការន្តធាតុត្រូវអាទេស ឯ ជា **អាយ** ពិតប្រាកដ ដូច **វិ** បុព្វបទ **ថេ** ធាតុសម្រេចរូបជា **វិត្ថាយតិ** ។ **ឈេ** ធាតុសម្រេចរូបជា **ឈាយតិ** ។

**-សោសោ** "រីងរៃ" ។

ត្រូវទទួលថា ÷ **នត្ថិ ភន្តេ** ។

**- អបមារោ** "ឆ្កួតជ្រូក" ។

ត្រូវទទួលថា ÷ **នត្ថិ ភន្តេ** ។

**- មនុស្សោសិ** "អ្នកជាមនុស្

ត្រូវទទួលថា ÷ **អាម ភន្តេ**

**-បុរិសោសិ** "អ្នកជាបុរសឬ ? ។

ត្រូវទទួលថា ÷ **អាម ភន្តេ** ។

**- ភុជិស្សោសិ** "អ្នកជាអ្នកជាឬ ? " ។

ត្រូវទទួលថា ÷ **អាម ភន្តេ** ។

**- អនណោសិ** "អ្នកមិនជំពាក់បំណុលគេទេឬ ?" ។

ត្រូវទទួលថា ÷ **អាម ភន្តេ** ។

**- នសិរាជភដោ** "អ្នកមិនមែនជាខ្ញុំរាជការទេឬ ?" ។

ត្រូវទទួលថា៖ **អាម ភន្តេ** ។

**- អនុញ្ញាតោសិ មាតាបិតូហិ** "អ្នកគឺមាតាបិតា អនុញ្ញាតហើយឬ ? ។

ទទួលថា **អាម ភន្តេ** ។

**-បរិបុណ្ណវីសតិវស្សោសិ**"អ្នកមានអាយុគ្រប់២០ឆ្នាំហើយឬ?"

ទទួលថា **អាម ភន្តេ** ។

**- បរិបុណ្ណន្តេ បត្តចីវរំ** "អ្នកមានបាត្រនិងចីវរគ្រប់គ្រាន់ ហើយឬ" ? ។

ទទួលថា **អាម ភន្តេ** ។

**- កិន្នាមោសិ** "អ្នកឈ្មោះអ្វី?" ។

ទទួលថា **អហំ ភន្តេ នាគោ នាម** ។

**- កោ នាមោ តេ ឧបជ្ឈាយោ ។**

ទទួលថា **ឧបជ្ឈាយោ មេ ភន្តេ អាយស្មា តិស្សត្ថេរោ នាម** ។

លុះសូត្រប្រៀនប្រដៅនាគហើយ ទើបឧបសម្បទាចារ្យត្រឡប់ចូលមកក្នុងកណ្ដាលការកសង្ឃវិញ ហើយសូត្រប្រកាសសង្ឃ និងហៅនាគឱ្យចូលមកថា ៖

**សុណាតុ មេ ភន្តេ(១) សង្ឃោ នាគោ អាយស្មតោ តិស្សស្ស ឧបសម្បទាបេក្ខោ ។ អនុសិដ្ឋោ សោ មយា ។ យទិ សង្ឃស្ស បត្តកល្លំ នាគោ អាគច្ឆេយ្យ ។**

ឈប់បង្អង់បន្តិចហើយ បក់ដៃហៅនាគថា **អាគច្ឆាហីតិ វត្តព្វោ, អាគច្ឆាហិ ។** នាគត្រូវដើរចូលទៅក្នុងជំនុំសង្ឃឈរត្រង់ទីចំពោះមុខព្រះឧបជ្ឈាយ៍ អង្គុយចុះក្រាបថ្វាយបង្គំព្រះឧបជ្ឈាយ៍ ឧបសម្បទាចារ្យនិងការកសង្ឃហើយផ្គងអញ្ជលី សូមឧបសម្បទាចំពោះនឹងការកសង្ឃដោយបញ្ចេញវចីភេទថា ៖

**សង្ឃម្ភន្តេ ឧបសម្បទំ យាចាមិ ឧល្លុម្បតុ មំ ភន្តេ សង្ឃោ អនុកម្បំ ឧបាទាយ ។ ទុតិយម្បិ ភន្តេ សង្ឃំ ឧបសម្បទំ យាចាមិ ឧល្លុម្បតុ មំ ភន្តេ សង្ឃោ អនុកម្បំ ឧបាទាយ ។**

---

(១)ក្នុងវិនយាលង្ការដីកា ភាគ ១ ទំព័រ ២៤៩ លោកបញ្ជាក់ថា ភិក្ខុដែលមានវស្សាច្រើនជាង កាលសូត្រត្រូវថា **ភន្តេ** , សម្រាប់ភិក្ខុខ្ចីត្រូវសូត្រថា **អាវុសោ** ។

**តតិយម្បិ ភន្តេ សង្ឃំ ឧបសម្បទំ យាចាមិ ឧល្លុម្បតុ មំ ភន្តេ សង្ឃោ អនុកម្បំ ឧបាទាយ ។**

កាលបើឧបសម្បទាបេក្ខៈសូត្រសូមរួចស្រេចហើយត្រូវ ឧបសម្ប-ទាចារ្យ គឺគ្រូសូត្រ សួរអន្តរាយិកធម៌ក្នុងកណ្តាលការកសង្ឃដូច្នេះថា ៖

**សុណាតុ មេ ភន្តេ សង្ឃោ អយំ នាគោ អាយស្មតោ តិស្សស្ស ឧបសម្បទាបេក្ខោ ។ យទិ សង្ឃស្ស បត្តកល្លំ អហំ នាគំ អន្តរាយិកេ ធម្មេ បុច្ឆេយ្យំ ។**

ហើយសួរដូច្នេះតទៅទៀតថា ៖

**សុណសិ នាគ អយន្តេ សច្ចកាលោ ភូតកាលោ យំ ជាតំ តំ បុច្ឆាមិ សន្តំ អត្ថីតិ វត្តព្វំ អសន្តំ នត្ថីតិ វត្តព្វំ សន្តិ តេ ឯវរូបា។**

ហើយសួរដូច្នេះតទៅទៀតថា ៖

**- កុដ្ឋំ** "ឃ្លង់" ។

ត្រូវទទួលថា **នត្ថិ ភន្តេ** ។

- **គណ្ឌោ** "ពក ឬ បូស" ។

ត្រូវទទួលថា **នត្ថិ ភន្តេ** ។

- **កិលាសោ** "រោគស្រែង" ។

ត្រូវទទួលថា **នត្ថិ ភន្តេ** ។

- **សោសោ** "រីងរៃ" ។

ត្រូវទទួលថា **នត្ថិ ភន្តេ** ។

- **អបមារោ** "ឆ្កួតជ្រូក" ។

ត្រូវទទួលថា **នត្ថិ ភន្តេ** ។

- **មនុស្សោសិ** "អ្នកជាមនុស្សឬ ?" ។

ត្រូវទទួលថា **អាម ភន្តេ** ។

-**បុរិសោសិ** "អ្នកជាបុរសឬ ? " ។

ត្រូវទទួលថា **អាម ភន្តេ** ។

- **ភុជិស្សោសិ** "អ្នកជាអ្នកជាឬ ?" ។

ទទួលថា **អាម ភន្តេ** ។

**- អនណោសិ** "អ្នកមិនជំពាក់បំណុលគេទេឬ ?" ។

ទទួលថា **អាម ភន្តេ** ។

**- នសិរាជភដោ** "អ្នកមិនមែនជាខ្ញុំរាជការទេឬ ? " ។

ទទួលថា **អាម ភន្តេ** ។

**- អនុញ្ញាតោសិ មាតាបិតូហិ** "អ្នកគឺមាតាបិតាអនុញ្ញាតហើយឬ ?" ។

ទទួលថា **អាម ភន្តេ** ។

**-បរិបុណ្ណវីសតិវស្សោសិ**"អ្នកមានអាយុគ្រប់២០ឆ្នាំហើយឬ?" ។

ទទួលថា **អាម ភន្តេ** ។

**- បរិបុណ្ណន្តេ បត្តចីវរំ** "អ្នកមានបាត្រនិងចីវរគ្រប់គ្រាន់ហើយឬ ?" ។

ទទួលថា **អាម ភន្តេ** ។

**- កិន្នាមោសិ** "អ្នកឈ្មោះអ្វី ?" ។

ទទួលថា **អហំ ភន្តេ នាគោ នាម** ។

**- កោ នាមោ តេ ឧបជ្ឈាយោ ។**

ទទួលថា **ឧបជ្ឈាយោ មេ ភន្តេ អាយស្មា តិស្សត្ថេរោ នាម** ។

លុះសួរអន្តរាយិកធម៌ក្នុងកណ្តាលការកសង្ឃហើយ បន្ទាប់មកត្រូវសូត្រញត្តិចតុត្ថកម្មវាចាតទៅទៀតថា ៖

**សុណាតុ មេ ភន្តេ សង្ឃោ, អយំ នាគោ អាយស្មតោ តិស្សស្ស ឧបសម្បទាបេក្ខោ, បរិសុទ្ធោ អន្តរាយិកេហិ ធម្មេហិ បរិបុណ្ណស្ស បត្តចីវរំ , នាគោ សង្ឃំ ឧបសម្បទំ យាចតិ អាយស្មតា តិស្សេន ឧបជ្ឈាយេន , យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ នាគំ ឧបសម្បាទេយ្យ អាយស្មតា តិស្សេន ឧបជ្ឈាយេន, ឯសា ញត្តិ ។**

**សុណាតុ មេ ភន្តេ សង្ឃោ, អយំ នាគោ អាយស្មតោ**

តិស្សស្ស ឧបសម្បទាបេក្ខោ, បរិសុទ្ធោ អន្តរាយិកេហិ ធម្មេហិ , បរិបុណ្ណស្ស បត្តចីវរំ , នាគោ សង្ឃំ ឧបសម្បទំ យាចតិ, អាយស្មតា តិស្សេន ឧបជ្ឈាយេន , សង្ឃោ នាគំ ឧបសម្បាទេតិ អាយស្មតា តិស្សេន ឧបជ្ឈាយេន , យស្សាយស្មតោ ខមតិ នាគស្ស ឧបសម្បទា, អាយស្មតា តិស្សេន ឧបជ្ឈាយេន, សោ តុណ្ហស្ស , យស្ស នក្ខមតិ សោ ភាសេយ្យ ។

ទុតិយម្បិ ឯតមត្ថំ វទាមិ ។

សុណាតុ មេ ភន្តេ សង្ឃោ, អយំ នាគោ អាយស្មតោ តិស្សស្ស ឧបសម្បទាបេក្ខោ, បរិសុទ្ធោ អន្តរាយិកេហិ ធម្មេ-ហិ , បរិបុណ្ណស្ស បត្តចីវរំ , នាគោ សង្ឃំ ឧបសម្បទំ យាចតិ អាយស្មតា តិស្សេន ឧបជ្ឈាយេន , សង្ឃោ នាគំ ឧបសម្បាទេតិ អាយស្មតា តិស្សេន ឧបជ្ឈាយេន , យស្សាយស្មតោ ខមតិ

នាគស្ស ឧបសម្បទា, អាយស្មតា តិស្សេន ឧបជ្ឈាយេន, សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។

តតិយម្បិ ឯតមត្ថំ វទាមិ ។

សុណាតុ មេ ភន្តេ សង្ឃោ, អយំ នាគោ អាយស្មតោ តិស្សស្ស ឧបសម្បទាបេក្ខោ, បរិសុទ្ធោ អន្តរាយិកេហិ ធម្មេហិ , បរិបុណ្ណស្ស បត្តចីវរំ , នាគោ សង្ឃំ ឧបសម្បទំ យាចតិ, អាយស្មតា តិស្សេន ឧបជ្ឈាយេន , សង្ឃោ នាគំ ឧបសម្បាទេតិ អាយស្មតា តិស្សេន ឧបជ្ឈាយេន , យស្សា-យស្មតោ ខមតិ នាគស្ស ឧបសម្បទា, អាយស្មតា តិស្សេន ឧបជ្ឈាយេន , សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។

ឧបសម្បន្នោ សង្ឃេន នាគោ, អាយស្មតា តិស្សេន ឧបជ្ឈាយេន , ខមតិ សង្ឃស្ស តស្មា តុណ្ហី , ឯវមេតំ ធារយាមិ[១] ។

(១)វិ.មហា.៦ / ៣១២ ។

លុះចប់ញត្តិចតុត្ថកម្មវាចាក្នុងខណៈណា ឧបសម្បទាបេក្ខៈនោះក៏បានស្ថិតនៅក្នុងភិក្ខុភាវៈគឺភេទជាភិក្ខុពេញបរិបូណ៌ក្នុងខណៈនោះ តាមពុទ្ធានុញ្ញាត ។ ពេលចប់ស្រេចឧបជ្ឈាយ៍ត្រូវចុះម៉ោងនាទីឱ្យច្បាស់លាស់លើសន្លឹកឆាយាតាមកំណត់នេះ ឱ្យភិក្ខុកាន់តទៅតាមបញ្ញត្តិសម្រាប់ប្រទេសកម្ពុជា ។

## ការពន្យល់បញ្ជាក់បន្ថែម

វិធីឧបសម្បទាខាងលើនេះជាកិច្ចងាយស្រួលក្នុងការឧបសម្ប័ទកុល-បុត្រមួយរូប, បើកុលបុត្រតែមួយគឺគ្រូសូត្រនោះតែមួយបានហើយ កុំសូត្រម្តងពីរនាំតែលំបាកស្មុគស្មាញ ។ ប្រសិនបើកុលបុត្រពីររូបអាចារ្យជាគ្រូសូត្រពីរដែរ ត្រូវកាន់យកកូនសិស្សម្នាក់មួយៗ ហើយពិធីសូត្រទៀតនិងវិធីបួសដូចខ្ញុំសរសេរមកនេះឯង មិនត្រូវផ្លាស់បាលីទេ តែពេលសូត្រញត្តិចតុត្ថកម្មវាចាត្រូវសូត្រឱ្យស្មើគ្នា មិនត្រូវឈប់មុនក្រោយគឺត្រូវធ្វើឱ្យស្មើគ្នារហូត ។ ដូចពាក្យថា **សុណាតុ មេ ភន្តេ សង្ឃោ** ជាដើម ត្រូវសូត្រឱ្យស្មើគ្នា បើថា **សុ** ឱ្យ **សុ** ស្មើគ្នា មិនមែនគ្រូសូត្រម្ខាងផ្តើមថា **សុណាតុ មេ ភន្តេ សង្ឃោ** ទើបគ្រូសូត្រម្ខាងទៀតបន្ត **អយំ នាគោ** ដូច្នេះឡើយ ។

វិធីឧបសម្បទាដូចខាងលើនេះ ជាការសន្មតិតំខណិកនាមជាបែបងាយស្រួលក្នុងការសូត្រ ទោះបីឧបសម្បទាចារ្យមិនសូវស្ទាត់បាលីក៏អាចសូត្របានមិនរអាក់រអួលទទាក់ទទាម ក្នុងកណ្តាលជំនុំសង្ឃ ។ ប៉ុន្តែបើឧបសម្បទាចារ្យ ដែលឈ្លាសប្រតិពលស្ទាត់ជំនាញអាចបញ្ចូលបាលីបានអាចផ្លាស់ឯកវចនៈជាពហុវចនៈបានមិនរអាក់រអួលទទាក់ទទាមហើយ ត្រូវការសូត្រ បកតិនាម គឺឈ្មោះឧបសម្បទាបេក្ខៈ និងឈ្មោះឧបជ្ឈាយ៍. ឧទាហរណ៍ដូចជា កុលបុត្រជាឧបសម្បទាបេក្ខៈនោះកាលដែលបួសបានជាសាមណេររួចហើយឧបជ្ឈាយ៍ឱ្យនាមបញ្ញត្តិថា **វជិរបញ្ញោ** ឯឧបជ្ឈាយ៍ ឈ្មោះ **រតនសារោ** ត្រូវសូត្រថា ៖

**សុណាតុ មេ ភន្តេ សង្ឃោ, វជិរបញ្ញោ អាយស្មតោ រតនសារស្ស ឧបសម្បទាបេក្ខោ ។បេ។ សុណសិ វជិរបញ្ញ អយន្តេ សច្ចកាលោ ភូតកាលោ ។បេ។ កិន្នាមោសិ, អហំ ភន្តេ វជិរបញ្ញោ នាម ។ កោ នាមោ តេ ឧបជ្ឈាយោ ។ ឧបជ្ឈាយោ មេ ភន្តេ អាយស្មា រតនសារោ នាម ។បេ។ សុណាតុ មេ ភន្តេ សង្ឃោ អយំ វជិរបញ្ញោ អាយស្មតោ រតនសារស្ស ឧបសម្បទាបេក្ខោ ។បេ។ ឧបសម្បន្នោ សង្ឃេន វជិរបញ្ញោ**

**អាយស្មតា រតនសារេន ឧបជ្ឈាយេន ។បេ។ ឯវមេតំ ធារ-យាមិ ។**

ប្រសិនបើឧបជ្ឈាយ៍មានឈ្មោះជាបាលីដែលមានស្រះ **ឥ- ឦ-** ឧ ឩ នៅខាងចុងដូចឈ្មោះថា **វក្កលិ, ធម្មទាយី, ធម្មគរុ, ធម្មញ្ញូ** ជាដើម ត្រូវសូត្រត្រង់ឆដ្ឋីវិភត្តិថា **អាយស្មតោ វក្កលិនោ, អាយស្មតោ ធម្មទាយិនោ, អាយស្មតោ ធម្មគរុនោ,អាយស្មតោ ធម្មញ្ញូនោ ។** ត្រង់តតិយាវិភត្តិត្រូវសូត្រថា **អាយស្មតា វក្កលិ, អាយស្មតា ធម្មទាយិនា, អាយស្មតា ធម្មគរុនា, អាយស្មតា ធម្មញ្ញូនា ឧបជ្ឈាយេន ។** ដូច្នេះ ឧបសម្បទាចារ្យដែលចេះបាលីមិនស្ទាត់សូត្រភ្លាមៗមិនកើតទេ លុះតែទន្ទេញបាលីសូត្រចេញឈ្មោះនេះ ឱ្យចាំស្ទាត់ទុកប៉ុន្មានពេលមុនហើយ ហាត់សូត្រឱ្យត្រាំតែស្ទាត់ នោះទើបអាចសូត្រកើត ។

# វិធីឧបសម្បទា

## (អាចារ្យ១រូប និង សិស្ស២ឬ៣រូប)

ការឧបសម្ប័ទនេះ ក៏ព្រះសម្មាសម្ពុទ្ធព្រះអង្គទ្រង់អនុញ្ញាតឱ្យអាចារ្យ១រូបអាចសូត្រកូនសិស្ស២ ឬ ៣រូបបានក្នុងខណៈតែមួយ មិនមានការទាស់ខុសនោះទេ ឱ្យតែឧបជ្ឈាយ៍តែមួយ ដូចព្រះអង្គទ្រង់អនុញ្ញាតនៅក្នុង វិនយបិដក មហាវគ្គ ៦/៣០៥ ថា **អនុជានាមិ ភិក្ខវេ ទ្វេ តយោ ឯកានុស្សាវនេ កាតុំ តញ្ច ខោ ឯកេន ឧបជ្ឈាយេន ន ត្វេវ នានុបជ្ឈាយេន ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុសូត្រអនុស្សាវនាជាមួយគ្នាចំពោះឧបសម្បទាបេក្ខៈពីរឬ បីរូបបាន តែការសូត្រអនុស្សាវនានោះបានតែដោយឧបជ្ឈាយ៍ជាមួយគ្នា ឧបជ្ឈាយ៍ផ្សេងគ្នាមិនបានឡើយ ។ ឱ្យតែឧបសម្បទាចារ្យ ឈ្លាសឆ្លាតអាចផ្លាស់បាលីឯកវចនៈជាពហុវចនៈបានមិនទាស់ខុសសោះឡើយហើយនៅក្នុង អដ្ឋកថា សមន្តប្បាសាទិកា ដីកា ក៏បានពន្យល់ដែរ យើងអាចកាន់យកសេចក្តីនោះបានហើយនឹងធ្វើនូវការឧបសម្បទាដោយនាគពីរឬបីតទៅខាងមុខនេះ ។

នៅក្នុងព្រះពុទ្ធដីកា និងអដ្ឋកថាបានពន្យល់យ៉ាងជាក់ច្បាស់ឥតមានសេចក្ដីអ្វី គួរឱ្យសង្ស័យចំពោះបញ្ហារឿងឧបសម្ប័ទ ដែលមានឧសម្បទាបេក្ខៈ ២ ឬ ៣ រូប ហើយអាចារ្យគឺគ្រូសូត្រ ១ រូបព្រមទាំងឧបជ្ឈាយ៍ ១ រូបនោះឡើយ ។ ប៉ុន្តែទោះបីឃើញជាក់ច្បាស់ថាបានក៏ដោយក៏នៅតែព្រះថេរៈអង្គខ្លះមិនហ៊ានសូត្របួសម្ដង២ ឬ ៣រូបឡើយ ព្រោះមិនទាន់មានលោកអ្នកប្រាជ្ញរៀបចំឧបសម្បទាបែបនោះឡើង ការខ្ញុំពិនិត្យសេចក្ដីលំបាកដល់ឧបសម្បទាចារ្យ ទើបខ្ញុំប្រមូលឯកសារមួយចំនួនមកធ្វើជាពិធីឧបសម្ប័ទ ដែលមានឧបសម្បទាចារ្យ ១ រូប សូត្រដល់សិស្ស ២ឬ៣ រូប ។

# ពិធីឧបសម្ប័ទសម្រាប់នាគគូ

អាចារ្យគឺគ្រូសូត្រសន្មតនាគមួយឈ្មោះ **នាគោ** នាគមួយទៀតឈ្មោះ **ទត្តោ** សន្មតឧបជ្ឈាយ៍ឈ្មោះ **តិស្សៈ** ។

ការសន្មតិរួចហើយគប្បីតាំង **នមោ** បីដងថា ៖

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។**

ចំណែកវិធីប្រាប់បាត្រជាដើម មានដូចតទៅនេះ ៖

**-ឥមេ វោ បត្តា**

**-ឥមា សង្ឃាដិយោ**

**-ឥមេ ឧត្តរាសង្គា**

**-ឥមេ អន្តរវាសកា**

នាគឆ្លើយថា **អាម ភន្តេ** អាចារ្យបន្តទៅទៀតថា ៖

**-គច្ឆថ អមុម្ហិ ឱកាសេ តិដ្ឋថ ។**

**ឧបសម្បទាបេក្ខះ**ត្រូវថយចេញទៅឱ្យផុតហត្ថបាសការកសង្ឃ ហើយឈរប្រណម្យអញ្ជលី, ហើយឧបសម្បទាចារ្យសូត្រប្រកាសសង្ឃថា៖

**សុណាតុ មេ ភន្តេ សង្ឃោ, នាគោ ច ទត្តោ ច អាយស្មតោ តិស្សស្ស ឧបសម្បទាបេក្ខា , យទិ សង្ឃស្ស បត្តកល្លំ អហំ នាគំ ច ទត្តំ ច អនុសាសេយ្យំ ។**

លុះសូត្រប្រកាសសង្ឃស្រេចហើយ ទើបលោកចេញទៅឈរ

ចំពោះមុខជិតគ្នានឹងនាគហើយត្រូវឧបសម្បទាចារ្យ សូត្រប្រៀនប្រដៅនាគ. ការសូត្រប្រៀនប្រដៅនាគនេះ ដូចខ្ញុំសរសេរតទៅនេះ ៖

**សុណាថ នាគទត្តា អយំ វោ សច្ចកាលោ ភូតកាលោ យំ ជាតំ តំ សង្ឃមជ្ឈេ បុច្ឆន្តេ សន្តំ អត្ថីតិ វត្តព្វំ ។ អសន្តំ នត្ថីតិ វត្តព្វំ ។ មា ខោ វិត្ថាយិត្ថ ។ មា ខោ មង្កុ អហោសិត្ថ ឯវំ វោ បុច្ឆិស្សន្តិ ។ សន្តិ វោ ឯវរូបា អាពាធា កុដ្ឋំ, គណ្ឌោ ,កិលាសោ, សោសោ, អបមារោ, មនុស្សាត្ថ, បុរិសាត្ថ, ភុជិស្សាត្ថ, អនណាត្ថ, នាត្ថ រាជភដា, អនុញ្ញាត្ថ មាតាបិតូហិ, បរិបុណ្ណវីសតិវស្សាត្ថ, បរិបុណ្ណំ វោ បត្តចីវរំ, កិន្នាមាត្ថ ។** ត្រូវឆ្លើយថា **អហំ ភន្តេ នាគោ នាម ។** នាគមួយទៀតថា **អហំ ភន្តេ ទត្តោ នាម ។ កោនាមោ វោ ឧបជ្ឈាយោ ។** ត្រូវឆ្លើយថា **ឧបជ្ឈាយោ នោ ភន្តេ អាយស្មា តិស្សត្ថេរោ នាម ។**

លុះសូត្រប្រៀនប្រដៅនាគរួចហើយ អាចារ្យគឺគ្រូសូត្រត្រឡប់

ចូលមកក្នុងកណ្តាលការកសង្ឃវិញ ហើយសូត្រប្រកាសសង្ឃ និង ហៅនាគឱ្យចូលមកថា ៖

**សុណាតុ មេ ភន្តេ សង្ឃោ, នាគោ ច ទត្តោ ច អាយស្មតោ តិស្សស្ស ឧបសម្បទាបេក្ខា, អនុសិដ្ឋា តេ មយា, យទិ សង្ឃស្ស បត្តកល្លំ, នាគោ ច ទត្តោ ច អាគច្ឆេយ្យុំ**

(ឈប់បន្តិចហើយបក់ដៃហៅថា) **អាគច្ឆថ ។**

សាមណេរទាំងនោះ ត្រូវដើរចូលមកអង្គុយក្នុងកណ្តាលការកសង្ឃ ត្រង់ទីចំពោះមុខព្រះឧបជ្ឈាយ៍ ធ្វើអភិវាទនកម្មថ្វាយបង្គំព្រះឧបជ្ឈាយ៍ ឧបសម្បទាចារ្យ និងការកសង្ឃ រួចហើយត្រូវអង្គុយច្រហោងប្រណម្យអញ្ជលី សូមឧបសម្បទាចំពោះនឹងការកសង្ឃដោយបញ្ចេញវចីភេទថា ៖

**សង្ឃម្ភន្តេ ឧបសម្បទំ យាចាម, ឧល្លុម្បតុ នោ ភន្តេ, សង្ឃោ អនុកម្បំ ឧបាទាយ ។**

**ទុតិយម្បិ ភន្តេ សង្ឃំ ឧបសម្បទំ យាចាម, ឧល្លុម្បតុ នោ ភន្តេ, សង្ឃោ អនុកម្បំ ឧបាទាយ ។**

**តតិយម្បិ ភន្តេ សង្ឃំ ឧបសម្បទំ យាចាម, ឧល្លុម្បតុ នោ ភន្តេ, សង្ឃោ អនុកម្បំ ឧបាទាយ ។**

លុះសាមណេរទាំងនោះសូត្រសូមយ៉ាងនេះហើយ ឧបសម្បទាចារ្យសន្មតិខ្លួន និងសួរអន្តរាយិកធម៌ក្នុងកណ្ដាលជំនុំសង្ឃថា ៖

**សុណាតុ មេ ភន្តេ សង្ឃោ, អយំ ច នាគោ អយំ ច ទត្តោ អាយស្មតោ តិស្សស្ស ឧបសម្បទាបេក្ខា, យទិ សង្ឃស្ស បត្តកល្លំ អហំ នាគំ ច ទត្តំ ច អន្តរាយិកេ ធម្មេ បុច្ឆេយ្យំ ។**

ការសួរអន្តរាយិកធម៌ក្នុងកណ្ដាលសង្ឃដូចគ្នានឹង ការសួរនៅខាងក្រៅការកសង្ឃដែរ ឯពាក្យសួរមានសង្ខេបដូចតទៅនេះ ៖

**សុណាថ នាគទត្តា, អយំ វោ សច្ចកាលោ ភូតកាលោ ។ល។ ឧបជ្ឈាយោ នោ ភន្តេ អាយស្មា តិស្សត្ថេរោ នាម ។**

លុះសូត្រសួរអន្តរាយិកធម៌ក្នុងកណ្ដាលជុំនុំសង្ឃស្រេចហើយ ទើបលោកសូត្រញត្តិចតុត្ថកម្មវាចាតទៅទៀតថា ៖

សុណាតុ មេ ភន្តេ សង្ឃោ, អយំ ច នាគោ អយំ ច ទត្តោ អាយស្មតោ តិស្សស្ស ឧបសម្បទាបេក្ខា,បរិសុទ្ធា អន្តរាយិកេហិ ធម្មេហិ, បរិបុណ្ណិមេសំ[(១)] បត្តចីវរំ, នាគោ ច ទត្តោ ច សង្ឃំ ឧបសម្បទំ យាចន្តិ, អាយស្មតា តិស្សេន ឧបជ្ឈាយេន, យទិ សង្ឃស្ស បត្តកល្លំ, សង្ឃោ នាគំ ច ទត្តំ ច ឧបសម្បាទេយ្យ, អាយស្មតា តិស្សេន ឧបជ្ឈាយេន ។ ឯសា ញត្តិ ។

សុណាតុ មេ ភន្តេ សង្ឃោ, អយំ ច នាគោ អយំ ច ទត្តោ អាយស្មតោ តិស្សស្ស ឧបសម្បទាបេក្ខា,បរិសុទ្ធា អន្តរាយិកេហិ ធម្មេហិ, បរិបុណ្ណិមេសំ បត្តចីវរំ,នាគោ ច ទត្តោ ច សង្ឃំ ឧបសម្បទំ យាចន្តិ, អាយស្មតា តិស្សេន

---

(១)**បរិបុណ្ណិមេសំ** នេះ មកពីពាក្យថា **បរិបុណ្ណំ** និង **ឥមេសំ** បានរូបជា **បរិបុណ្ណិមេសំ** លុបនិគ្គហិតចេញព្រោះស្រះខាងក្រោយ ។

ឧបជ្ឈាយេន, សង្ឃោ នាគំ ច ទត្តំ ច ឧបសម្បាទេតិ, អាយស្មតា តិស្សេន ឧបជ្ឈាយេន, យស្សាយស្មតោ ខមតិ នាគស្ស ច ទត្តស្ស ច ឧបសម្បទា, អាយស្មតា តិស្សេន ឧបជ្ឈាយេន, សោ តុណ្ហស្ស, យស្ស នក្ខមតិ, សោ ភាសេយ្យ ។

ទុតិយម្បិ ឯតមត្ថំ វទាមិ

សុណាតុ មេ ភន្តេ សង្ឃោ, អយំ ច នាគោ អយំ ច ទត្តោ អាយស្មតោ តិស្សស្ស ឧបសម្បទាបេក្ខា,បរិសុទ្ធា អន្តរាយិកេហិ ធម្មេហិ, បរិបុណ្ណិមេសំ បត្តចីវរំ, នាគោ ច ទត្តោ ច សង្ឃំ ឧបសម្បទំ យាចន្តិ, អាយស្មតា តិស្សេន ឧបជ្ឈាយេន, សង្ឃោ នាគំ ច ទត្តំ ច ឧបសម្បាទេតិ, អាយស្មតា តិស្សេន ឧបជ្ឈាយេន,យស្សាយស្មតោ ខមតិ នាគស្ស ច ទត្តស្ស ច ឧបសម្បទា, អាយស្មតា តិស្សេន ឧបជ្ឈាយេន, សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។

វិធីឧបសម្បទាដូចខាងលើនេះ ជាការសន្មតិតំខណិកនាមជាបែបងាយស្រួល ក្នុងការសូត្រ ទោះបីឧបសម្បទាចារ្យមិនសូវស្ទាត់បាលីក៏អាចសូត្របានមិនរអាក់រអួលទទាក់ទទាម ក្នុងកណ្តាលជំនុំសង្ឃ ។ ប៉ុន្តែបើឧបសម្បទាចារ្យ ដែលឈ្លាសប្រតិពលស្ទាត់ជំនាញអាចបញ្ចូលបាលីបានអាចផ្លាស់ឯកវចនៈជាពហុវចនៈបានមិនរអាក់រអួលទទាក់ទទាមហើយ ត្រូវការសូត្រ បកតិនាម គឺឈ្មោះឧបសម្បទាបេក្ខៈ និងឈ្មោះឧបជ្ឈាយ៍. ឧទាហរណ៍ដូចជា កុលបុត្រជាឧបសម្បទាបេក្ខៈនោះកាលដែលបួសបានជាសាមណេររួចហើយឧបជ្ឈាយ៍ឱ្យនាមបញ្ញត្តិថា **វជិរបញ្ញោ** ឯឧបជ្ឈាយ៍ ឈ្មោះ **រតនសារោ** ត្រូវសូត្រថា ÷

**សុណាតុ មេ ភន្តេ សង្ឃោ, វជិរបញ្ញោ អាយស្មតោ រតនសារស្ស ឧបសម្បទាបេក្ខោ ។បេ។ សុណសិ វជិរបញ្ញ អយន្តេ សច្ចកាលោ ភូតកាលោ ។បេ។ កិន្នាមោសិ, អហំ ភន្តេ វជិរបញ្ញោ នាម ។ កោ នាមោ តេ ឧបជ្ឈាយោ ។ ឧបជ្ឈាយោ មេ ភន្តេ អាយស្មា រតនសារោ នាម ។បេ។ សុណាតុ មេ ភន្តេ សង្ឃោ អយំ វជិរបញ្ញោ អាយស្មតោ រតនសារស្ស ឧបសម្បទាបេក្ខោ ។បេ។ ឧបសម្បន្នោ សង្ឃេន វជិរបញ្ញោ**

**អាយស្មតា រតនសារេន ឧបជ្ឈាយេន ។បេ។ ឯវមេតំ ធារ-យាមិ ។**

ប្រសិនបើឧបជ្ឈាយ៍មានឈ្មោះជាបាលីដែលមានស្រះ **ឥ- ឦ-** ឧ ឩ នៅខាងចុងដូចឈ្មោះថា **វក្កលិ, ធម្មទាយី, ធម្មគរុ, ធម្មញ្ញូ** ជាដើម ត្រូវសូត្រត្រង់ឆដ្ឋីវិភត្តិថា **អាយស្មតោ វក្កលិនោ, អាយស្មតោ ធម្មទាយិនោ, អាយស្មតោ ធម្មគរុនោ,អាយស្មតោ ធម្មញ្ញូនោ ។** ត្រង់តតិយាវិភត្តិត្រូវសូត្រថា **អាយស្មតា វក្កលិ, អាយស្មតា ធម្មទាយិនា, អាយស្មតា ធម្មគរុនា, អាយស្មតា ធម្មញ្ញូនា ឧបជ្ឈាយេន ។** ដូច្នេះ ឧបសម្បទាចារ្យដែលចេះបាលីមិនស្ទាត់សូត្រភ្លាមៗមិនកើតទេ លុះតែទន្ទេញបាលីសូត្រចេញឈ្មោះនេះ ឱ្យចាំស្ទាត់ទុកប៉ុន្មានពេលមុនហើយ ហាត់សូត្រឱ្យត្រាំតែស្ទាត់ នោះទើបអាចសូត្រកើត ។

ភូមា- មន ក៏គេបំបួសកុលបុត្រដោយវិធីសន្មតឧបសម្បទាបេក្ខៈជា **នាគ** ឧបជ្ឈាយ៍ជា **តិស្សៈ** ដែរ និងក្នុងគម្ពីរវិនយាលង្ការដីកាក៏បានបញ្ជាក់យ៉ាងច្បាស់លាស់ដែរ ។

តាមខ្ញុំសិក្សាមកបានដឹងថា កាលពី ព.ស. ២៥០២ ខែពិសាខ ឆ្នាំកុរ ឯកស័ក ត្រូវនឹងឆ្នាំ ១៩៥៩ សម្ដេចព្រះមហាសុមេធាធិបតី **ជោតញាណោ ជួន ណាត** សម្ដេចព្រះសង្ឃរាជគណៈមហានិកាយ បានទៅធ្វើជាឧបជ្ឈាយ៍បំបួសកុលបុត្រនៅប្រទេស ឥណ្ឌូណេស៊ី រួមជាមួយនិងគណៈសង្ឃ លង្កា-ភូមា-ថៃ ក៏បានប្រើវិធីបំបួសការសន្មតិ **តំខណិកនាម** គឺ **នាគ** និង **តិស្សៈ** នេះឯង ។ ប៉ុន្តែបើឧបសម្បទា ២ រូប សូមឧបសម្បទាដំណាលគ្នា គេច្រើនដាក់ **ច**-សព្ទថា **នាគោ ច នាគោ ច អាយស្មតោ តិស្សស្ស ឧបសម្បទាបេក្ខា ។បេ។ អយញ្ច នាគោ អយញ្ច នាគោ ។បេ។** (នៅត្រង់ពាក្យថា **នាគោ ច នាគោ ច** ត្រូវគ្រូសូត្រយកម្រាមចង្អុលចំនាគនោះៗឱ្យដឹងថា តើនាគណាត្រូវបួស) ។

បើតាមបែបងាយស្រួលក្នុងការឧបសម្ប័ទ នាគ ២ ឬ ៣ រូប ក្នុងពេលជាមួយគ្នា គួរតែព្រះថេរៈគ្រប់កន្លែងសន្មតអ្នកត្រូវបួសថា **នាគ** សន្មតឧបជ្ឈាយ៍ថា **តិស្សៈ** ទាំងអស់តែម្តងទៅ ។

## ទ្វិឧបសម្បទាបេក្ខទ្វន្ទសមាសុបសម្បទកម្មវាចា (១)

## តាំងញត្តិទី១

**សុណាតុ មេ ភន្តេ សង្ឃោ, ឥមេ នាគទត្តា អាយស្មតោ តិស្សស្ស ឧបសម្បទាបេក្ខា,បរិសុទ្ធា អន្តរាយិកេហិ ធម្មេហិ, បរិបុណ្ណមេសំ បត្តចីវរំ, នាគទត្តា សង្ឃំ ឧបសម្បទំ យាចន្តិ, អាយស្មតា តិស្សេន ឧបជ្ឈាយេន, យទិ សង្ឃស្ស បត្តកល្លំ, សង្ឃោ នាគទត្តេ ឧបសម្បាទេយ្យ, អាយស្មតា តិស្សេន ឧបជ្ឈាយេន ។ ឯសា ញត្តិ ។**

---

(១) កាលបើចាប់សូត្រញត្តិត្រូវឱ្យឧបសម្បទាបេក្ខៈនៅក្នុងហត្ថបាសជាប់នឹងការកសង្ឃ ព្រោះក្នុងគម្ពីរវិនយាលង្ការដីកា (១/២៥០) ប្រាប់ថា ឧបសម្បទាបេក្ខោ អនុបសម្បន្នោ ហត្ថបាសេ ឋបេតព្វោ ។

### អនុស្សាវនានី ១

សុណាតុ មេ ភន្តេ សង្ឃោ, ឥមេ នាគទត្តា អាយស្មតោ តិស្សស្ស ឧបសម្បទាបេក្ខា,បរិសុទ្ធា អន្តរាយិកេហិ ធម្មេហិ, បរិបុណ្ណិមេសំ បត្តចីវរំ, នាគទត្តា សង្ឃំ ឧបសម្បទំ យាចន្តិ, អាយស្មតា តិស្សេន ឧបជ្ឈាយេន, សង្ឃោ នាគទត្តេ ឧបសម្បាទេតិ, អាយស្មតា តិស្សេន ឧបជ្ឈាយេន, យស្សាយស្មតោ ខមតិ នាគទត្តានំ ឧបសម្បទា, អាយស្មតា តិស្សេន ឧបជ្ឈាយេន, សោ តុណ្ហស្ស, យស្ស នក្ខមតិ, សោ ភាសេយ្យ ។

### អនុស្សាវនានី ២

ទុតិយម្បិ ឯតមត្ថំ វទាមិ...។

### អនុស្សាវនានី ៣

តតិយម្បិ ឯតមត្ថំ វទាមិ ...។

### ឧបសម្បទាបេក្ខៈបួសស្រេចហើយ

ឧបសម្បន្នា សង្ឃេន, នាគទត្តា អាយស្មតា តិស្សេន ឧបជ្ឈាយេន ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។

ប្រសិនបើអាចារ្យចង់បំបួសសូត្រម្តងពរូបគឺកំណត់នាគទី១ ឈ្មោះថា**នាគ** នាគទី២ថា **ទត្តៈ** នាគទី៣ថា **មិត្តៈ** គប្បីសូត្រដូចតទៅៈ-

### តាំងញត្តិទី ១[១]

សុណាតុ មេ ភន្តេ សង្ឃោ, ឥមេ នាគទត្តមិត្តា អាយស្មតោ តិស្សស្ស ឧបសម្បទាបេក្ខា, បរិសុទ្ធា អន្តរាយិកេហិ ធម្មេហិ, បរិបុណ្ណិមេសំ បត្តចីវរំ, នាគទត្តមិត្តា សង្ឃំ ឧបសម្បទំ យាចន្តិ, អាយស្មតា តិស្សេន ឧបជ្ឈាយេន, យទិ សង្ឃស្ស បត្តកល្លំ, សង្ឃោ នាគទត្តមិត្តេ ឧបសម្បាទេយ្យ, អាយស្មតា តិស្សេន ឧបជ្ឈាយេន ។ ឯសា ញត្តិ ។

---

(១) កាលបើចាប់សូត្រញត្តិ ត្រូវឱ្យឧបសម្បទាបេក្ខៈស្ថិតនៅក្នុងហត្ថបាសជាប់នឹងការកសង្ឃ ព្រោះក្នុងគម្ពីរវិនយាលង្ការដីកា (១/២៥០ ) ប្រាប់ថា ឧបសម្បទាបេក្ខោ អនុបសម្បន្នោ ហត្ថបាសេ ឋបេតព្វោ ។

### អនុស្សាវនាទី ១

សុណាតុ មេ ភន្តេ សង្ឃោ, ឥមេ នាគទត្តមិត្តា អាយស្មតោ តិស្សស្ស ឧបសម្បទាបេក្ខា,បរិសុទ្ធា អន្តរាយិកេហិ ធម្មេហិ,បរិបុណ្ណិមេសំ បត្តចីវរំ, នាគទត្តមិត្តា សង្ឃំ ឧបសម្បទំ យាចន្តិ,អាយស្មតា តិស្សេន ឧបជ្ឈាយេន, សង្ឃោ នាគទត្តមិត្តេ ឧបសម្បាទេតិ, អាយស្មតា តិស្សេន ឧបជ្ឈាយេន, យស្សា-យស្មតោ ខមតិ នាគទត្តមិត្តានំ ឧបសម្បទា, អាយស្មតា តិស្សេន ឧបជ្ឈាយេន, សោ តុណ្ហស្ស, យស្ស នក្ខមតិ, សោ ភាសេយ្យ ។

### អនុស្សាវនាទី២

ទុតិយម្បិ ឯតមត្ថំ វទាមិ...។

### អនុស្សាវនាទី៣

តតិយម្បិ ឯតមត្ថំ វទាមិ ...។

**ឧបសម្បទាបេក្ខៈបួសស្រេចហើយ**

**ឧបសម្បន្នោ សង្ឃេន, នាគទត្តមិត្តា អាយស្មតា តិស្សេន ឧបជ្ឈាយេន ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។**

បើឧសម្បទាចារ្យមិនចង់ឱ្យលំបាកស្មូតស្មាញទេគ្រាន់តែកំណត់ថា ឧបសម្បទាបេក្ខៈនេះ ជានាគទី ១ នាគទី២ ឬជានាគទី៣ ហើយសូត្រយក ឥមេ នាគា តែម្តងជាការស្រេច ។

**១**

**សុណាតុ មេ ភន្តេ សង្ឃោ , ឥមេ នាគា អាយស្មតោ តិស្សស្ស ឧបសម្បទាបេក្ខា,បរិសុទ្ធា អន្តរាយិកេហិ ធម្មេហិ, បរិបុណ្ណមេសំ បត្តចីវរំ, នាគា សង្ឃំ ឧបសម្បទំ យាចន្តិ, អាយស្មតា តិស្សេន ឧបជ្ឈាយេន, យទិ សង្ឃស្ស បត្តកល្លំ, សង្ឃោ នាគេ ឧបសម្បាទេយ្យ, អាយស្មតា តិស្សេន ឧបជ្ឈាយេន ។ ឯសា ញត្តិ ។**

**អនុស្សាវនានី ១**

សុណាតុ មេ ភន្តេ សង្ឃោ, ឥមេ នាគា អាយស្មតោ តិស្សស្ស ឧបសម្បទាបេក្ខា,បរិសុទ្ធា អន្តរាយិកេហិ ធម្មេហិ, បរិបុណ្ណមេសំ បត្តចីវរំ, នាគា សង្ឃំ ឧបសម្បទំ យាចន្តិ, អាយស្មតា តិស្សេន ឧបជ្ឈាយេន, សង្ឃោ នាគេ ឧបសម្បាទេតិ, អាយស្មតា តិស្សេន ឧបជ្ឈាយេន, យស្សាយស្មតោ ខមតិ នាគានំ ឧបសម្បទា, អាយស្មតា តិស្សេន ឧបជ្ឈាយេន, សោ តុណ្ហស្ស, យស្ស នក្ខមតិ, សោ ភាសេយ្យ ។

**អនុស្សាវនានី ២**

ទុតិយម្បិ ឯតមត្ថំ វទាមិ...។

**អនុស្សាវនានី ៣**

តតិយម្បិ ឯតមត្ថំ វទាមិ ...។

**ឧបសម្បន្នោ សង្ឃេន, នាគោ អាយស្មតា តិស្សេន ឧបជ្ឈាយេន ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។**

ឧបសម្បទាបត្ត:បួសស្រេចហើយ

កម្មវាចាឧបសម្បទានេះត្រឹមត្រូវតាមច្បាប់វិនយបិដកត្រង់បទបាលីថា **អសុវជិបុនញ្ញសុកា** ជាកម្មវាចាជាប់ទាក់ទងនឹងបព្វាជនីយកម្ម (វិនយ-បិដក៩/៦៥ ) ។

# អនុសាសនវិធី

អនុសាសនៈ គឺការប្រៀនប្រដៅភិក្ខុថ្មី ដែលយើងធ្លាប់ហៅថា ផ្តាំនាគ នេះជាមុខនាទីរបស់ឧបជ្ឈាយ៍ ត្រូវឧបជ្ឈាយ៍ប្រាប់ខ្លួនឯង តែបើឧបជ្ឈាយ៍ការប្រើភិក្ខុដែលឈ្លាសប្រតិពលឱ្យប្រាប់ជំនួសខ្លួនក៏បាន ។ ត្រូវសូត្រប្រាប់ជាបាលីនិងប្រែឱ្យស្តាប់សេចក្តីបាន ត្រូវប្រាប់ពេលដែលបួសហើយភ្លាម ។ សូមបញ្ជាក់បន្តិចត្រង់បាលីថា **តេ** បើច្រើនអង្គផ្លាស់ជា **វោ** ។

ឯ **និស្ស័យ** ៤យ៉ាង វិនយធរគប្បីប្រាប់ថា ៖

**១- បិណ្ឌិយាលោបភោជនំ និស្សាយ បព្វជ្ជា តត្ថ តេ យាវជីវំ ឧស្សាហោ ករណីយោ** "អ្នកបួសត្រូវអាស្រ័យនូវភោជនជាពំនូត១ គឺអាហារមានប្រមាណ ១វែក ២វែកជាដើម ដែលទាយកគេដាក់ក្នុងបាត្រ ដែលបានមកដោយកម្លាំងស្មង គឺដែលបានមកដោយដើរទៅបិណ្ឌបាត. សេចក្តីព្យាយាមក្នុងការបរិភោគនូវបិណ្ឌិយាលោបភោជននោះ អ្នកគប្បីធ្វើសព្វ១ថ្ងៃ ដរាបដល់អស់ជីវិត ។

**អតិរេកលាភោ សង្ឃភត្តំ ឧទ្ទេសភត្តំ និមន្តនំ សលាកភត្តំ បក្ខិកំ ឧបោសថិកំ បាដិបទិកំ** "ភត្តជាអតិរេកលាភ៧ យ៉ាងគឺ សង្ឃភត្ត១ ឧទ្ទេសភត្ត១ និមន្តនភត្ត១ សលាកភត្ត១ បក្ខិកភត្ត១ ឧបោសថិកភត្ត១ បាដិបទិកភត្ត១ (ភត្តជាអតិរេកលាភទាំង៧យ៉ាងនេះ បើអ្នកបានហើយ អ្នកគប្បីបរិភោគដោយធម៌ចុះ)" ។

នវកភិក្ខុទទួលថា :

**អាម ភន្តេ** "ករុណាលោកម្ចាស់" ។

**២- បំសុកូលចីវរំ និស្សាយ បព្វជ្ជា តត្ថ តេ យាវជីវំ ឧស្សាហោ ករណីយោ** "អ្នកបួសត្រូវអាស្រ័យនូវបំសុកូលចីវរ គឺសំពត់ដែលសៅហ្មងដោយអាចមដី ដោយធូលី, សេចក្ដីព្យាយាមក្នុងការប្រើប្រាស់នូវសំពត់បំសុកូលចីវរនោះ អ្នកគប្បីធ្វើដរាបដល់អស់ជីវិត ។

**អតិរេកលាភោ ខោមំ កប្បាសិកំ កោសេយ្យំ កម្ពលំ សាណំ ភង្គំ** "សំពត់ជាអតិរេកលាភ៦យ៉ាងគឺ សំពត់ដែលគេត្បាញដោយសរសៃឈើ១ សំពត់ដែលគេត្បាញដោយអំបោះ១ សំពត់ដែលគេត្បាញដោយសូត្រ១ សំពត់ដែលគេត្បាញដោយរោមសត្វ១ សំពត់ដែលគេត្បាញដោយសំបកធ្មៃ១ សំពត់ដែលគេយករបស់ទាំង៥គឺ សរសៃឈើ អំបោះ សូត្រ រោមសត្វ សំបកធ្មៃ មកលាយច្រឡំគ្នាហើយត្បាញ១ (សំពត់ជាអតិរេកលាភទាំង៦យ៉ាងនេះ បើអ្នកបានហើយ អ្នកគប្បីប្រើប្រាស់ដោយធម៌មិចុះ)" ។

**នវក** ភិក្ខុត្រូវទទួលថា :-

**អាម ភន្តេ** "ករុណាលោកម្ចាស់" ។

**៣- រុក្ខមូលសេនាសនំ និស្សាយ បព្វជ្ជា តត្ថ តេ យាវជីវំ ឧស្សាហោ ករណីយោ** "អ្នកបួស ត្រូវអាស្រ័យនៅក្រោមម្លប់ឈើជាសេនាសនៈ គឺទីដេកទីអង្គុយ, សេចក្តីព្យាយាមក្នុងការអាស្រ័យនូវរុក្ខមូលសេនាសនៈនោះ អ្នកគប្បីធ្វើដរាបដល់អស់ជីវិត" ។

**អតិរេកលាភោ វិហារោ អឌ្ឍយោគោ បាសាទោ ហម្មិយំ គុហា** "សេនាសនៈជាអតិរេកលាភ៥យ៉ាងនេះគឺ :- ទីអាវាសដែលបិទបាំងដោយរបង ឬកំពែងព័ទ្ធជុំវិញ គឺទីវត្តទាំងមូល១ ប្រាសាទមានសណ្ឋានវែង ឬ សណ្ឋានដូចជាខ្នងដំរី ឬក៏ដូចរូបគ្រុឌ ឬសេនាសនៈដែលមានដំបូលតែម្ខាង គឺបង្ហា១ ប្រាសាទមានជ្រុង៤ហើយមានជាន់ច្រើន១ ប្រាសាទមានដំបូលរលីង គឺប្រាសាទប្រក់បូក ឬ ផ្ទះមានកំពូល១ គុហាដែលគេធ្វើដោយឥដ្ឋ ដោយថ្ម ដោយឈើ ដោយអាចម៍ដី ឬ គុហាដែលកើតឯងក្នុងភ្នំ១ (សេនាសនៈជាអតិរេកលាភទាំង៥យ៉ាងនេះ បើអ្នកបានហើយ អ្នកគប្បីអាស្រ័យដោយធម៌ចុះ)" ។

**នវក** ភិក្ខុទទួលថា :-

**អាម ភន្តេ** " ករុណាលោកម្ចាស់" ។

**៤- បូតិមុត្តភេសជ្ជំ និស្សាយ បព្វជ្ជា តត្ថ តេ យាវជីវំ ឧស្សាហោ ករណីយោ** "អ្នកបួស ត្រូវអាស្រ័យនូវទឹកមូត្រ គឺទឹកមូត្រគោ ជាថ្នាំរម្ងាប់រោគ, សេចក្តីព្យាយាមក្នុងការអាស្រ័យនូវទឹកមូត្រនោះ អ្នកគប្បីធ្វើដរាបដល់អស់ជីវិត " ។

**អតិរេកលាភោ សប្បិ នវនីតំ តេលំ មធុ ផាណិតំ** "ភេសជ្ជៈជាអតិរេកលាភ៥យ៉ាងគឺ ទឹកដោះថ្លា១ ទឹកដោះខាប់១ ប្រេង១ ទឹកឃ្មុំ១ ទឹកអំពៅ១ (ភេសជ្ជៈជាអតិរេកលាភ ៥យ៉ាងនេះ បើអ្នកបាន ហើយអ្នកគប្បីអាស្រ័យដោយធម៌ចុះ)" ។

**នវក** ភិក្ខុទទួលថា :-

**អាម ភន្តេ** " ករុណាលោកម្ចាស់" ។

**ឯអករណីយកិច្ច ៤យ៉ាងវិន័យធរគប្បីប្រាប់ថា**

**១- ឧបសម្បន្នេន ភិក្ខុនា មេថុនោ ធម្មោ ន បដិសេវិតព្វោ អន្តមសោ តិរច្ឆានគតាយបិ** "មេថុនធម្ម គឺភិក្ខុដែលបាន

ឧបសម្បទាហើយ មិនត្រូវសេពឡើយ ដោយហោចទៅសូម្បីសត្វតិរច្ឆាន ក៏សេពពុំបាន" ។ **យោ ភិក្ខុ មេថុនំ ធម្មំ បដិសេវតិ, អស្សមណោ ហោតិ អសក្យបុត្តិយោ** "ភិក្ខុណាមួយសេពនូវមេថុនធម្ម (ភិក្ខុនោះ) មិនមែនជាសមណៈ មិនមែនជាសក្យបុត្តិយ៍ឡើយ" ។ **សេយ្យថាបិ នាម បុរិសោ សីសច្ឆិន្នោ អភព្វោ តេន សរីរពន្ធនេន ជីវិតុំ, ឯវមេវ ភិក្ខុ មេថុនំ ធម្មំ បដិសេវិត្វា អស្សមណោ ហោតិ អសក្យបុត្តិយោ**"បុរសដែលមានក្បាលដាច់ហើយ មិនអាចដើម្បីនឹងរស់នៅ ដោយកិរិយាតភ្ជាប់សរីរៈនោះបាន ដូចម្ដេចមិញ, ភិក្ខុដែលសេពនូវមេថុធម្មហើយ ក៏មិនមែនជាសមណៈ មិនមែនជាសក្យបុត្តិយ៍ដូច្នោះឯង" ។ **តន្តេ យាវជីវំ អករណីយំ** "អ្នកមិនត្រូវសេពនូវមេថុធម្មនោះដរាបដល់អស់ជីវិត " ។

**នវក** ភិក្ខុទទួលថា :-

**អាម ភន្តេ** " ករុណាលោកម្ចាស់" ។

**២- ឧបសម្បន្នេន ភិក្ខុនា អទិន្នំ ថេយ្យសង្ខាតំ ន អាទាតព្វំ អន្តមសោ តិណសលាកំ ឧបាទាយ** "ភិក្ខុដែលបានឧបសម្បទាហើយ មិនត្រូវកាន់យកនូវទ្រព្យដែលគេមិនបានឱ្យដោយកាយ ឬដោយវាចា ដោយចំណែកនៃចិត្តលួចនោះឡើយ ដោយហោចទៅ សូម្បីតែស្មៅ១បាច់ក៏យកពុំបាន " ។ **យោ ភិក្ខុ បាទំ វា បាទារហំ វា អតិរេកបាទំ វា អទិន្នំ ថេយ្យសង្ខាតំ អាទិយតិ, អស្សមណោ ហោតិ អសក្យបុត្តិយោ** "ភិក្ខុឯណាមួយកាន់យកវត្ថុមានតម្លៃ១បាទក្តី គួរដល់ថ្លៃ១បាទក្តី ឬថ្លៃជាង១បាទឡើងទៅក្តី ដែលគេមិនបានឱ្យដោយកាយ ឬដោយវាចា ដោយចំណែកនៃចិត្តលួច, (ភិក្ខុនោះ) មិនមែនជាសមណៈ មិនមែនជាសក្យបុត្តិយ៍ឡើយ " ។

**សេយ្យថាបិ នាម បណ្ឌុបលាសោ ពន្ធនា បមុត្តោ អភព្វោ ហរិតត្ថាយ,ឯវមេវ ភិក្ខុ បាទំ វា បាទារហំ វា អតិរេកបាទំ វា អទិន្នំ ថេយ្យសង្ខាតំ អាទិយិត្វា អស្សមណោ ហោតិ អសក្យបុត្តិយោ** " ស្លឹកឈើទុំ មានពណ៌លឿង ដែលជ្រុះចាកទងហើយ

មិនអាចដើម្បីត្រឡប់ជា មានពណ៌ខៀវឡើងវិញ ដូចម្តេចមិញ,ភិក្ខុដែលកាន់យកនូវវត្ថុមានតម្លៃ ១បាទក្តី គួរដល់ថ្លៃ ១បាទក្តី ឬថ្លៃជាង ១បាទឡើងទៅក្តី ដែលគេមិនបានឱ្យដោយកាយ ឬដោយវាចា ដោយចំណែកនៃចិត្តលួចក៏មិនមែនជាសមណៈ មិនមែនជាសក្យបុត្តិយ៍ ដូច្នេះឯង"។ **តន្តេ យាវជីវំ អករណីយំ** "អ្នកមិនត្រូវកាន់យកនូវរបស់ដែលគេមិនបានឱ្យដោយកាយ ឬដោយវាចា ដរាបដល់អស់ជីវិត "។

**នវក** ភិក្ខុទទួលថា :-

**អាម ភន្តេ** " ករុណាលោកម្ចាស់" ។

**៣- ឧបសម្បន្នេន ភិក្ខុនា សញ្ចិច្ច បាណោ ជីវិតា ន វោរោបេតព្វោ អន្តមសោ កុន្ថកិបិល្លិកំ ឧបាទាយ** "សត្វមានជីវិតគឺភិក្ខុដែលបានឧបសម្បទាហើយមិនត្រូវក្លែងសម្លាប់ឱ្យផុតចាកជីវិតឡើយ ដោយហោចទៅ សូម្បីតែស្រមោចខ្មៅនិងស្រមោចក្រហម ក៏សម្លាប់ពុំបាន "។ **យោ ភិក្ខុ សញ្ចិច្ច មនុស្សវិគ្គហំ ជីវិតា វោរោបេតិ**

**អន្តមសោ គព្ភបាតនំ ឧបាទាយ អស្សមណោ ហោតិ អសក្យបុត្តិយោ** "ភិក្ខុឯណាមួយក្លែងសម្លាប់សត្វមានរាងកាយជាមនុស្ស ឱ្យផុតចាកជីវិត ដោយហោចទៅ សូម្បីតែញ៉ាំងគភ៌នៃមនុស្សឱ្យធ្លាក់ចុះ (ភិក្ខុនោះ) មិនមែនជាសមណៈ មិនមែនជាសក្យបុត្តិយ៍ឡើយ " ។ **សេយ្យថាបិ នាម បុថុសិលា ទ្វេធា ភិន្នា អប្បដិសន្ធិកា ហោតិ, ឯវមេវ ភិក្ខុ សញ្ចិច្ច មនុស្សវិគ្គហំ ជីវិតា វោរោបេត្វា អស្សមណោ ហោតិ អសក្យបុត្តិយោ** "ថ្មតាន់ដ៏ក្រាស់ ដែលបែកចេញជា២ភាគ នឹងតឱ្យជាប់វិញពុំបាន ដូចម្តេចមិញ, ភិក្ខុក្លែងសម្លាប់សត្វមានរាងកាយជាមនុស្សឱ្យផុតចាកជីវិតហើយ ក៏មិនមែនជាសមណៈ មិនមែនជាសក្យបុត្តិយ៍ឡើយ ដូច្នោះឯង" ។ **តន្តេ យាវជីវំ អករណីយំ** "អ្នកមិនត្រូវក្លែងសម្លាប់សត្វ មានរាងកាយជាមនុស្សនោះដរាបដល់អស់ជីវិត " ។

**នវក** ភិក្ខុទទួលថា :-

**អាម ភន្តេ** " ករុណាលោកម្ចាស់" ។

**៤- ឧបសម្បន្នេន ភិក្ខុនា ឧត្តរិមនុស្សធម្មោ ន ឧល្លបិតព្វោ អន្តមសោ សុញ្ញាគារេ អភិរមាមីតិ** "ឧត្តរិមនុស្សធម្ម គឺភិក្ខុដែលបាន ឧបសម្បទាហើយ មិនត្រូវពោលអួតឡើយ ដោយហោច ទៅសូម្បីតែពោលថា ខ្ញុំត្រេកអរតែក្នុងសុញ្ញាគារស្ថាន គឺទីសេនាសនៈ ដ៏ស្ងាត់ ដូច្នេះក៏ពុំបាន ។

**យោ ភិក្ខុ បាបិច្ឆោ ឥច្ឆាបកតោ អសន្តំ អភូតំ ឧត្តរិមនុស្សធម្មំ ឧល្លបតិ ឈានំ វា វិមោក្ខំ វា សមាធឹ វា សមាបត្តឹ វា មគ្គំ វា ផលំ វា, អស្សមណោ ហោតិ អសក្យបុត្តិយោ** " ភិក្ខុឯណាមានសេចក្តីប្រាថ្នាលាមក គឺសេចក្តី លោភគ្របសង្កត់រួបរឹតហើយ ពោលអួតនូវឧត្តរិមនុស្សធម៌ គឺឈានក្តី វិមោក្ខក្តី សមាធិក្តី សមាបត្តិក្តី មគ្គក្តី ផលក្តី ដែលមិនមានពិតដល់ខ្លួន, (ភិក្ខុនោះ) មិនមែនជាសមណៈ មិនមែនជាសក្យបុត្តិយ៍ឡើយ" ។

**សេយ្យថាបិ នាម តាលោ មត្ថកច្ឆិន្នោ អភព្វោ បុន វិរុឡ្ហិយា, ឯវមេវ ភិក្ខុ បាបិច្ឆោ ឥច្ឆាបកតោ អសន្តំ អភូតំ**

**ឧត្តរិមនុស្សធម្មំ ឧល្លបិត្វា អស្សមណោ ហោតិ អសក្យបុត្តិយោ**
"ដើមត្នោតដែលមានចុងកំបុតត្រឹមកហើយ មិនអាចនឹងលូតលាស់ដុះចំរើនឡើងបាន ដូចម្តេចមិញ, ភិក្ខុដែលមានសេចក្តីប្រាថ្នាលាមក គឺសេចក្តីលោភគ្របសង្កត់រួបរឹតហើយ ពោលអួតនូវឧត្តរិមនុស្សធម៌ ដែលមិនមានក្នុងខ្លួន ក៏មិនមែនជាសមណៈ មិនមែនជាសក្យបុត្តិយ៍ដូច្នោះឯង" ។

**តន្តេ យាវជីវំ អករណីយំ** "អ្នកមិនត្រូវពោលនូវឧត្តរិមនុស្សធម៌នោះ ដរាបដល់អស់ជីវិត ។

**នវក** ភិក្ខុទទួលថា :-

**អាម ភន្តេ** " ករុណាលោកម្ចាស់" ។

អនុសាសនវិធីនេះ ត្រូវឱ្យកុលបុត្រសិក្សាតែក្នុងអករណីយកិច្ច៤ យ៉ាងខាងចុង ឱ្យចាំស្ទាត់ចូលចិត្តស្តាប់សេចក្តីបានជាមុន ។ ឯនិស្ស័យ ៤ យ៉ាងខាងដើមមិនគួរនឹងសិក្សាឱ្យដឹងជាមុនទេ ។

**ចប់អនុសាសនវិធីតែប៉ុណ្ណោះ**

# ឧបសម្បទាវិធីចប់បរិបូណ៌

# និគមនកថា

យំ សិទ្ធំ ឥមិនា បុញ្ញំ យញ្ចញ្ញំ បសុតំ មយា
ឯតេន បុញ្ញកម្មេន សីឃំ បប្បោមិ និព្វុតំ
អប្បត្តោ យាវ និព្វានំ ភវេយ្យំ ជាតិជាតិយំ
មហាបញ្ញាយ សម្បន្នោ ជោតេយ្យំ ជិនសាសនំ
កាចតីសេ បមោទនោ សីលាចារគុណេ រតោ
អលគ្គោ បញ្ចកាមេះ ឈាន បឋមំ ផលំ
អន្តិមេ អគ្គកាចម្ភិ ភ្តេយ្យំ មុនិបុង្គវំ
លោកគ្គបុគ្គលំ នាថំ ...្វសត្តហិតេ រតំ
និព្វាន តស្ស ធីរស្ស សុត្វា សទ្ធម្មទេសនំ
អធិគន្ត្វា ផលំ អគ្គំ សោភេយ្យំ ជិនសាសនំ ។

ដោយអំណាចផលបុណ្យដែលកើតអំពីការរចនាសៀវភៅនេះក្តី ដោយបុញ្ញកម្មដទៃដែលខ្ញុំសន្សំមកហើយក្តី សូមឱ្យខ្ញុំបន្លុះព្រះនិព្វានដោយឆាប់រហ័សបើសិនជាខ្ញុំមិនទាន់បន្លុះនូវព្រះនិព្វានដរាបណាសូមឱ្យខ្ញុំជាអ្នកដល់ព្រមដោយបញ្ញាអាច

ប្រកាសសាសនាព្រះជិនស្រីឱ្យរុងរឿងរហូតគ្រប់ៗ
ជាតិ ។ ក្នុងអត្តភាពទី២ សូមឱ្យខ្ញុំរីករាយក្នុងស្ថាន
តាវតឹង្សត្រេកអរក្នុងគុណ គឺ សីលនិងអាចារៈមិន
ជាប់ជំពាក់ក្នុងកាមគុណ ៥ ហើយសូមឱ្យខ្ញុំបន្ទុះផល
ទី ១ , ក្នុងអត្តភាពចុងបំផុតបង្អស់សូមឱ្យខ្ញុំបានគាល់
ព្រះមេត្តេយ្យសម្មាសម្ពុទ្ធជា អគ្គបុគ្គល ជាទីពឹង
ទ្រង់ជាអ្នកត្រេកអរក្នុងការផ្ទុងផ្ដើមដល់សត្វទាំងពួង
ពេលនោះ ខ្ញុំបានស្ដាប់សទ្ធម្មទេសនា ដែលព្រះអង្គ
ជាអ្នកប្រាជ្ញទ្រង់សំដែង សូមឱ្យខ្ញុំបានសម្រេចនូវ
ផលដ៏លើសគឺអរហត្តផលហើយខ្ញុំគប្បីជាអ្នកញ៉ាំង
សាសនា ព្រះជិនស្រីអង្គនោះឱ្យរុងរឿង ។

សូមសេចក្ដីប្រាថ្នារបស់ខ្ញុំ ( វ៉ាន់ ចាន់សារ៉ែន ) បានសម្រេចតាមបំណេងប៉ង
ប្រាថ្នា ដោយបុញ្ញកម្មដែលខ្ញុំបានធ្វើហើយ ក្នុងសាសនាព្រះសម្មាសម្ពុទ្ធ
ទ្រង់ព្រះនាមសមណគោតមនេះ ។

# ឯកសារពិគ្រោះ

១. **ព្រះវិនយបិដក មហាវគ្គ លេខ ៦** បោះពុម្ពលើកទី ២ របស់ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ព.ស.២៤៩៩ ។

២. **អដ្ឋកថា សមន្តប្បាសាទិកា ក្បាលលេខ ៣** ច្បាប់មហាចុឡា បោះពុម្ព ព.ស.២៥៣៤ ក្រុងទេពមហានគរ ។

៣. **វជិរពុទ្ធិដីកា** ច្បាប់មហាចុឡា ។

៤. **សារត្ថទីបនីដីកា ភាគ ៣** ច្បាប់មហាចុឡា បោះពុម្ព ព.ស.២៥៣៨ ៗ

៥. **វិមតិវិនោទនីដីកា ភាគ ២** ច្បាប់មហាចុឡា ។

៦. **វិនយាលង្ការដីកា ភាគ ១** ច្បាប់មហាចុឡា ។

៧. **បញ្ហាខន្ធកសង្ខេប** សម្តេច ល្វី ឯម ។

៨. **នានាវិនិច្ឆ័យ** ព្រះធម្មានន្ទៈ មហាថេរៈ អគ្គមហាបណ្ឌិត ជនជាតិ ភូមា ។

**៩. ពុទ្ធចិន្ដាគួរដឹង** ដោយព្រះជោតិបាលោ (ស្វែង) បោះពុម្ពនៅខេត្ត នន្ទបុរី ប្រទេសថៃ ព.ស.២៥៤៥ ។

**១០.** ឯកសារជាច្រើនទៀត ។

ការទទួលយកទៅបោះពុម្ពផ្សាយជាធម្មទាន

ក្រោមការឧបត្ថម្ភបោះពុម្ពរបស់មូលនិធិពុទ្ធិកសិក្សានៅតៃវ៉ាន់

(The Corporate Body of the Buddha Educational Foundation) ។

ដោយអាស្រ័យលើការមើលឃើញនូវកត្តាចាំបាច់មួយចំនួនដូចខាងក្រោម៖

- រក្សាស្នាដៃវប្បធម៌ព្រះពុទ្ធសាសនាឲ្យគង់វង្សស្ថិតស្ថេរ
- តម្រូវការរបស់សិក្ខាកាមអ្នកប្រាថ្នាចង់យល់ដឹងនូវខ្លឹមសារពុទ្ធសាសនា
- ផ្សាយនូវធម្មទាន ធ្វើឲ្យព្រះពុទ្ធសាសនាកាន់តែមានភាពរីកចម្រើនរុង-រឿងក្នុងលោក

ក្នុងករណីដែលលោកអ្នកអានបានប្រទះឃើញនូវសៀវភៅនេះមានដាក់លក់

នៅកន្លែងណា ឬចង់បានសៀវភៅធម៌យកទៅអាន

សូមទាក់ទងមកយើងខ្ញុំតាមអាសយដ្ឋានដូចខាងក្រោមៈ

វត្តបញ្ញា សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ

លេខទូរស័ព្ទៈ (៨៥៥) ១២ ៩៦១ ៤២៩, (៨៥៥) ៨៨៧ ៩៦១ ៤២៩

អ៊ីមែលៈ maha.panna@gmail.com

គេហទំព័រៈ http://www.mahapanna.org

# DEDICATION OF MERIT

May the merit and virtue
accrued from this work
adorn Amitabha Buddha's Pure Land,
repay the four great kindnesses above,
and relieve the suffering of
those on the three paths below.

May those who see or hear of these efforts
generate Bodhi-mind,
spend their lives devoted to the Buddha Dharma,
and finally be reborn together in
the Land of Ultimate Bliss.
Homage to Amita Buddha!

**NAMO AMITABHA**

**南無阿彌陀佛**

《東埔寨文：The Higher Ordination, 受具足戒儀軌》

財團法人佛陀教育基金會 印贈

台北市杭州南路一段五十五號十一樓

Printed and donated for free distribution by

**The Corporate Body of the Buddha Educational Foundation**

11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.

Tel: 886-2-23951198 , Fax: 886-2-23913415

Email: overseas@budaedu.org

Website:http://www.budaedu.org

Mobile Web: m.budaedu.org

**This book is strictly for free distribution, it is not to be sold.**

សម្រាប់ចែកជាធម្មទាន

Printed in Taiwan

3,000 copies; September 2015

CA061 - 13498